ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអប្សរា
APSARA

លេខ ១០៨៧ / អ.ល.ស.ផ.ល
១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់សម្ភារៈការិយាល័យ ជូនអាជ្ញាធរអប្សរា ប្រចាំឆ្នាំ២០១៨

អាជ្ញាធរអប្សរាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស(គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា៖ អាជ្ញាធរអប្សរានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់សម្ភារៈការិយាល័យ ជូនអាជ្ញាធរអប្សរា ប្រចាំឆ្នាំ២០១៨ ។

អាជ្ញាធរអប្សរា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមាន ដាក់លក់នៅអង្គភាពលទ្ធកម្មអាជ្ញាធរអប្សរា ដែលមានអាសយដ្ឋានក្នុងភូមិបង្កោង សង្កាត់អំពិល ក្រុងសៀមរាប ចាប់ពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ០៦៣ ២១០ ៦១៥) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ០៨ម៉ោង០០ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មអាជ្ញាធរអប្សរា តាមអាសយដ្ឋានខាងលើ វេលាម៉ោង០៨ម៉ោង០០ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបាន តែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ពុធ ១៥កើត ខែ អស្សុជ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅសៀមរាប ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៨

**អគ្គនាយកអាជ្ញាធរអប្សរា**
**និងជាអនុប្រធានគណៈកម្មាធិការលទ្ធកម្ម**

ស៊ុំ ម៉ាប់

**ចម្លងជូន៖**
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ កាលប្បវត្តិ



Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh